សុន្ទរកថារបស់ **លោក តាស៊ីយ៉ា ម៉ាជីដា** ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោង ទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
របស់ប្រទេសជប៉ុន

០៩ មិនា ២០១២

**សូមគោរព លោក បិនយ៉ាមីន ង្វៀង នាយកកម្មវិធីប្រចាំតំបន់នៃអង្គការជនពិការអន្តរជាតិ (HIF)!**
**លោក ឡៅ វេង ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយHIFសម្រាប់គម្រោងជំនួយទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិនាថ្ងៃនេះ។

ខ្ញុំបានដឹងថា នៅប្រទេសកម្ពុជាមានកុមារជាច្រើនដែលត្រូវក្លាយជាពិការដោយសារតែគ្រាប់មីនដែលនៅសេសសល់កាលពីសម័យសង្គ្រាម ហើយក៏មានកុមារមួយចំនួនទៀតដែលទទួលរងគ្រោះដោយសារជំងឺគ្រុនស្វិតដៃជើងពីកំណើត ឬកំឡុងពេលដែលពួកគេនៅជាទារកនៅឡើយ។ ខ្ញុំបានលឺថា ជាអកុសលពួកគេមួយចំនួនត្រូវបានបោះបង់ចោលនៅផ្ទះដោយមិនបានទទួលការព្យាបាល និងស្តារនីតិសម្បទាឡើងវិញឲ្យបានត្រឹមត្រូវឡើយ។

តាមរយៈការស្នើសុំរបស់HIF និងការអង្កេតដល់ទីកន្លែងដែលធ្វើឡើងដោយបុគ្គលិកស្ថានទូត យើងទទួលស្គាល់នូវតម្រូវការបន្ទាន់ក្នុងការកែលម្អ ពង្រីកហេដ្ឋារចនាសម្ព័ន្ធក្នុងអគារនៃមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តកំពង់ចាមដើម្បីផ្តល់សេវាស្តារលទ្ធភាពពលកម្មឲ្យបានត្រឹមត្រូវដល់ជនពិការ។ ជាក់ស្តែង រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ជំនួយដែលមានទឹកប្រាក់សរុបចំនួន ៣៩,៥០០ ដុល្លាអាមេរិក សម្រាប់គម្រោង កែលម្អមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តកំពង់ចាម។

យើងសង្ឃឹមថា ការសាងសង់ពង្រីក និងកែលម្អមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មនេះ នឹងជួយឲ្យអតិថិជនពិការប្រមាណ៣,០០០នាក់អាចទទួលបានសេវាស្តារលទ្ធភាពពលកម្មយ៉ាងត្រឹមត្រូវ។ ខ្ញុំដឹងថា HIFនឹងផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធក្នុងមជ្ឈមណ្ឌលដើម្បីសម្រួលដល់ការបម្លាស់ទីរបស់ជនពិការ។ ការពង្រីកបន្ទប់ព្យាបាលដោយចលនានឹងអនុញ្ញាតឲ្យអតិថិជនពិការកាន់តែច្រើនអាចទទួលបាននូវភាពងាយស្រួលជាងមុនក្នុងការហ្វឹកហាត់ចលនាកាយសម្បទា។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូនដោយ HIF និងថែរក្សាយ៉ាងត្រឹមត្រូវដោយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តកំពង់ចាម។ ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!